ព្រះគម្ពីរសំរាប់កុមារ

សូមបង្ហាញជូន

# ឫទ្ធិបាដិហារិយ៍របស់ព្រះយេស៊ូ



និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ Byron Unger; Lazarus Alastair Paterson

កែសម្រួលដោយ៖ E. Frischbutter; Sarah S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2023 Bible for Children, Inc.

អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

ព្រះយេស៊ូបានសម្តែងឫទ្ធិបាដិហារិយ៍ជាច្រើន។ ឫទ្ធិបាដិហារិយ៍ទាំងនោះ ជាទីសម្គាល់បញ្ជាក់ថា ព្រះយេស៊ូពិតជា ព្រះបុត្រារបស់ព្រះជាម្ចាស់ប្រាកដមែន។ ឫទ្ធិបាដិហារិយ៍ទីមួយបានកើតឡើងនៅក្នុងពិធីជប់លៀងក្នុងមង្គលការមួយ។ មាន បញ្ហាមួយបានកើតឡើងនៅទីនោះ។ ម្ចាស់ដើមការខ្វះស្រាទទួលភ្ញៀវដែលចូលរួមមង្គលការ។



នាងម៉ារា ជាម្ដាយរបស់ព្រះយេស៊ូ បានទូលព្រះអង្គអំពីបញ្ហានោះ
បន្ទាប់មកនាងបានប្រាប់អ្នកបម្រើឲ្យធ្វើតាមអ្វីដែលព្រះ
យេស៊ូបង្គាប់ឲ្យធ្វើ។



ព្រះយេស៊ូមានព្រះបន្ទូលថា ៖ “ចូរដងទឹកមកចាក់ឲ្យពេញពាងទាំងនេះ” ។ ប្រហែលគេអាចសួរបញ្ជាក់ថា ៖ “ដងទឹក?” ព្រះយេស៊ូបញ្ជាក់បន្ថែមថា “ត្រូវហើយគឺដងទឹក”។



បន្ទាប់មកទៀត ព្រះយេស៊ូបង្គាប់ឲ្យអ្នកបម្រើដួសទឹកពីពាងមួយក្នុងចំណោមពាងជាច្រើនយកទៅជូនលោកចៅមហា
ដែលទទួលរៀបចំពិធីមង្គលការនោះដើម្បីភ្លក្សទឹកនោះ។
ទឹកនោះបានក្លាយជាស្រាទំពាំង
បាយជូរ ជាស្រាដ៏ល្អ គឺស្រាល្អបំផុត។



អ្នកបម្រើមានការងឿងឆ្ងល់យ៉ាងខ្លាំង។ ព្រះយេស៊ូបានប្រែទឹកឲ្យទៅជាស្រាទំពាំងបាយជូរ។

មានតែព្រះជាម្ចាស់ប៉ុណ្ណោះ   អាចសម្ដែងឫទ្ធិបាដិហារិយ៍ដូច្នេះ   បាន។



ព្រះយេស៊ូបានសម្តែងឫទ្ធិបាដិហារិយ៍ផ្សេងៗទៀតជាច្រើន។

នៅល្ងាចមួយនោះ ព្រះអង្គ និង ក្រុមសាវ័ករបស់ព្រះ

អង្គបានយាងទៅលេងផ្ទះរបស់លោកពេត្រុស។

ម្តាយក្មេងរបស់លោកមានជម្ងឺគ្រុណក្តៅយ៉ាងខ្លាំង។



ព្រះយេស៊ូ បានពាល់ដៃអ្នកជម្ងឺនោះ។ រំពេចនោះនាងក៏បានជាសះស្បើយឡើងវិញ។

នាងបានក្រោកឡើង ហើយបម្រើ ព្រះយេស៊ូ និង ក្រុមសាវ័ក។



មើលទៅទំនងជាមានមនុស្សទាំងអស់ក្នុងក្រុងនោះប្រមូលផ្តុំគ្នានៅ
មាត់ទ្វារផ្ទះក្នុងល្ងាចនោះហើយ។ មនុស្សឈឺ, មនុស្សខ្វាក់,
មនុស្សគ, មនុស្សថ្លង់ និង
មនុស្សពិការជាច្រើននាក់ផង។
មានទាំងមនុស្សដែលមាន
ខ្មោចចូលជាច្រើនបាន
មករកព្រះយេស៊ូ។
តើព្រះអង្គអាចជួយបានទេ
បើមានមនុស្សច្រើន
យ៉ាងនេះនោះ?



ព្រះយេស៊ូ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ ព្រះអង្គអាចជួយបាន គ្រប់គ្នា។

ព្រះយេស៊ូបានជួយគ្រប់គ្នាដែលចូលមករកព្រះអង្គ។ អស់អ្នកដែលមករកព្រះអង្គទាំងប៉ុន្មាន

បានទទួលការប្រោស ឲ្យជាគ្រប់ៗគ្នា។ មនុស្សពិការភាពទាំងអស់ ពេលនេះអាចដើរ

រត់ និង លោតបាន។



អ្នកជំងឺផ្សេងៗទៀតក៏បានមកដល់ដែរ គឺអស់អ្នកដែលមិន
បរិសុទ្ធដោយជំងឺឃ្លង់។



ព្រះយេស៊ូប្រោសគេឲ្យបានជាស្អាតទាំងស្រុង។



មនុស្សប្រុស និង មនុស្សស្រីដែលមានខ្មោចចូល បានក្រោកឈរឡើងនៅចំពោះព្រះយេស៊ូ។ ព្រះអង្គដេញខ្មោចឲ្យចេញពីមនុស្ស ទាំងនោះ។ កាលខ្មោចបានស្ដាប់បង្គាប់េ



មនុស្សដែលមិនធ្លាប់រីករាយ

បែរត្រឡប់ជារីករាយ និង

មានចិត្តស្ងប់ឡើងវិញ។

នៅពីក្រោយហ្វូងមនុស្សដ៏ច្រើននោះ មានបុរសបួននាក់បានប្រឹងប្រែងរកមធ្យោបាយនាំមិត្តភក្តិរបស់គេមករកព្រះយេស៊ូ។ ប៉ុន្តែគេមិនអាចចូលទៅជិតព្រះយេស៊ូបានទេ។ តើគេនឹងធ្វើអ្វី ដើម្បីនាំមិត្តភក្តិរបស់គេទៅរកព្រះយេស៊ូបាន?



អ្នកទាំងបួននាក់បានសែងអ្នកជំងឺឡើងទៅលើដំបូលផ្ទះ មិត្តដ៏ស្មោះត្រង់ទាំងនោះបាន
ចោះដំបូលរួចក៏សម្រូតអ្នកជំងឺទៅរកព្រះ អង្គ។ ឥឡូវនេះ
គាត់បានចូលមកជិតព្រះ យេស៊ូហើយ។



ព្រះយេស៊ូទតឃើញថា មិត្តភក្តិទាំងបួននាក់មានជំនឿមាំមួនណាស់។ ព្រះអង្គមានព្រះបន្ទូលទៅបុរសដែលឈឺនោះថា ៖

“ខ្ញុំលើកលែងទោសឲ្យ
អ្នកបានរួចពីបាបហើយ
ចូរក្រោកឡើង
យកគ្រែស្នែងរបស់អ្នក
ហើយដើរទៅចុះ”។

បុរសនោះក៏ក្រោកឡើងទាំងមានសុខភាពល្អ និង រឹងមាំផង។ ព្រះយេស៊ូបានប្រោសគាត់ឲ្យបានជាសះស្បើយ។



លុះបន្តិចក្រោយមក ព្រះយេស៊ូបានចុះទូលយាងទៅ ក្រោយម្ខាងជាមួយក្រុមសាវ័ក។ រំពេចនោះ ក៏មានខ្យល់ព្យុះបក់បោកមកលើសមុទ្រយ៉ាងខ្លាំង។ ចំណែកឯព្រះយេស៊ូវិញ កំពុងតែផ្ទំលក់នៅឯកន្សៃ ទូកឯណោះ។ ក្រុមសាវ័កដែលពោរពេញ ដោយការភ័យខ្លាច បានដាស់ព្រះអង្គឲ្យតើនឡើង។ ពួកគេស្រែកថា ៖ “ព្រះអម្ចាស់អើយ! សូមសង្គ្រោះយើងខ្ញុំផង យើងខ្ញុំវិនាសឥឡូវហើយ!”។



ព្រះយេស៊ូតើនឡើងហើយគំរាមខ្យល់ព្យុះថា ៖ ចូរស្ងប់ឲ្យឈប់ចុះ!។ រំពេចនោះ សមុទ្រក៏ស្ងប់។ ពួកសាវ័ករបស់ព្រះអង្គខ្សឹបសួរគ្នាថា ៖ តើលោកនេះជានរណា បានជាខ្យល់ និង សមុទ្រស្ដាប់បង្គាប់លោកដូច្នេះ? ពួកគេជឿជាក់ថា ព្រះយេស៊ូ ពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ប្រាកដមែន ព្រោះព្រះអង្គបានសម្ដែង ឫទ្ធិបាដិហារិយ៍ និង បង្ហាញសិរីរុងរឿងរបស់ព្រះអង្គ។ ពួកសាវ័កមិនបានយល់ពីកិច្ចការទាំងនោះទេ ប៉ុន្តែពួកគេប្រាកដជានឹងបានឃើញព្រះយេស៊ូសម្ដែងឫទ្ធិបាដិហារិ៍ដ៏ធំជាច្រើន ក្នុងពេលដែលព្រះអង្គធ្វើកិច្ចការរបស់ព្រះជាម្ចាស់នៅកណ្ដាលចំណោមមនុស្សលោក។



ឫទ្ធិបាដិហារិយ៍របស់ព្រះយេស៊ូ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់,

អាចរកឃើញនៅក្នុងព្រះគម្ពីរ

ម៉ាថាយ ៨-៩, ម៉ាកុស ១-២,

លូកា ៤, លូកា ៨, យ៉ូហាន ២

“ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គ ធ្វើឲ្យមនុស្សភ្លឺស្វាង ហើយធ្វើឲ្យអ្នកទន់ទាបមានប្រាជ្ញា។”
ទំនុកតម្កើង 119:130

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថាជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្ដីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម៉្លេះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះអំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូ ទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគតជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូមទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូលបង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់ ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគុម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ! យូហាន ៣:១៦